# កាក់ និងការវិវត្តក្នុងកម្ពុជាបុរាណ

ពាក្យថាកាក់មានន័យថា ជាឈ្មោះប្រាក់ដែលប្រើក្នុងប្រទេសកម្ពុជា មាន៣យ៉ាង គឺ ១០សេន ២០សេន និង៥០សេន។[១] ជាទូទៅកាក់ជា វត្ថុធ្វើអំពីលោហៈ ដែលប្រើប្រាស់សម្រាប់ទូទាត់ឬដោះដូរក្នុងមុខជំនួញ ឬការងារផ្សេងៗ តាំងពីសម័យបុរាណមកទល់បច្ចុប្បន្ន (នៅមានប្រើប្រាស់ក្នុងប្រទេសមួយចំនួន រីឯកម្ពុជាពុំបានប្រើទៀតទេ)។

## តើកាក់មានវត្តមានពីពេលណាក្នុងសង្គមខ្មែរ?

យើងពុំមានកស្តុតាងជាក់លាក់ណាមួយបង្ហាញពី វត្តមានកាក់របស់កម្ពុជានាសម័យបុរាណ ពិសេសសម័យមុនប្រវត្តិសាស្ត្រ សម័យមុនអង្គរ និងសម័យអង្គរនោះទេ ប៉ុន្តែតាមការស្រាវជ្រាវ និងធ្វើកំណាយជាលើកដំបូងរបស់លោក ល្វីស ម៉ាឡេរ៉េ នៅស្ថានីយអូរកែវ[២] (ក្រោយមកគេច្រើនហៅអូកែវ តាមសំណេរអក្សរបារាំង Oc-Éo) នៅឆ្នាំ ១៩៤៥ បានបង្ហាញពីវត្តមានកាក់បរទេសមួយចំនួនដែលត្រូវបាននាំចូល និងប្រើប្រាស់ក្នុងសង្គមខ្មែរ ឬជាអតីតទឹកដីកម្ពុជានាសម័យនោះ។ កាក់ចំនួន២ ក្នុងចំណោមកាក់ទាំងនោះលោក ម៉ាឡេរ៉េ បង្ហាញថា មានប្រភពមកពីប្រទេសរ៉ូម៉ាំង កាក់ទី១គឺក្នុងជំនាន់ស្តេចឈ្មោះ Antoninus Pius (AD 138-161) និងកាក់១ទៀតស្ថិតក្នុងសម័យអ្នកស្នងរាជ្យបន្តពីគាត់ឈ្មោះ Marcus Aurelius (AD 161-180) (រូបលេខ១)។[៣] កាក់ដែលរកឃើញនៅអូរកែវមានសណ្ឋានដូចគ្នាទៅនឹងកាក់ដទៃទៀត ដែលគេបានជួបប្រទះនៅតំបន់អាស៊ីអាគ្នេយ៍ ពិសេសនៅតណ្ហាខាងត្បូង។ កាក់ធ្វើអំពីមាស ប្រាក់ និងលង្ហិនជាច្រើនរកឃើញនៅតណ្ហា និងកាក់មួយទៀតផលិតនៅក្នុងសម័យអធិរាជរ៉ូម៉ាំង ឈ្មោះ Victorinius (3rd Century AD) រកឃើញនៅ U-Thong (រូបលេខ២)[៤] ក្នុងប្រទេសថៃសព្វថ្ងៃ បង្ហាញពីទំនាក់ទំនងរវាង

---

[១] ជួន ណាត ១៩៦៧:៣១

[២] Malleret Louis: 1959b

[៣] Charles Higham 2002:236

[៤] Bérénice Bellina and Ian Glover, (2004:71).

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ឥណ្ឌា និងតំបន់មេឌីទែរ៉ាណេ ជាមួយនឹងតំបន់អាស៊ីអាគ្នេយ៍តាមរយៈពាណិជ្ជកម្ម។ ការរកឃើញកាក់ដូច ឬស្រដៀងគ្នានៅតាមតំបន់ផ្សេងៗ បង្ហាញថា វាត្រូវបានគេប្រើប្រាស់ក្នុងផ្លូវជំនួញ។[៥] ក្រៅពីកាក់របស់រ៉ូម៉ាំង មានកាក់ខ្លះបង្ហាញពីរូប ដែលអាចមានប្រភពមកពីឥណ្ឌា។ កាក់ផ្សេងទៀត ដែលរកឃើញនៅបាថេ (វៀតណាម) មានរូបសត្វ ហើយមានលក្ខណៈដូចគ្នាទៅនឹងកាក់ដែលរកបានពីកំណាយរបស់លោក ម៉ាឡេរ៉េ (រូបលេខ៣)។[៦]

ក្នុងសង្គមខ្មែរនាសម័យបុរាណពិសេសមុនអង្គរ និងអង្គរគឺពុំមានវត្ថុមានកាក់ត្រូវបានរកឃើញនៅឡើយទេ។ តាមរយៈសិលាចារឹកជាច្រើន បង្ហាញថាខ្មែរបានប្រើមាស ឬប្រាក់ (ជាចំនួន ឬទម្ងន់) សម្រាប់ដោះដូរ ឬធ្វើពាណិជ្ជកម្មផ្សេងៗ។ ប៉ុន្តែមានកាក់២មានសណ្ឋានជាសន្ទឹកមាស ហើយត្រូវបានគេគិតថាជាកាក់ក្នុងសតវត្សទី៨ ដោយសារមានព្រះនាមស្ដេច ឈ្មោះ ស្រីសានវរ្ម៍ (ស្រីឥសានវរ្ម័ន) (រូបលេខ៤)។[៧] កាក់មួយទៀតជាវត្ថុឯកជន និងក្នុងសារមន្ទីរបាងកក ហើយត្រូវបានគេសន្និដ្ឋានថា ជាកាក់ធ្វើពីសំរឹទ្ធនាសម័យអាណាចក្រអង្គរ (រូបលេខ៥)។[៨] នៅសម័យក្រោយអង្គរ ពិសេសចាប់ពីសតវត្សទី១៦ឬ១៧ គឺមានវត្ថុមានកាក់ជាច្រើនដែលត្រូវបានគេរក្សាទុកជាឯកជន។ កាក់ទាំងនោះត្រូវបានគេរៀបចំចំណាត់ថ្នាក់ ដោយពុំមានពត៌មានឬកស្តុតាងពីកំណាយបុរាណវិទ្យាអ្វីឡើយ។ នៅក្នុងសៀវភៅរូបិយវត្ថុកម្ពុជា គេបានធ្វើចំណាត់ថ្នាក់កាក់កម្ពុជាពីឆ្នាំ១៥១៦ (ក្នុងរាជព្រះបាទអង្គចន្ទ ១៥១៦ដល់១៥៦៦) ដល់ឆ្នាំ១៨៤៦ គឺមុនសម័យអាណានិគមបារាំង។[៩] ក្នុងចំណោមកាក់ដែលគេចំណាត់ថ្នាក់ទាំងនោះ មានកាក់មួយចំនួនដែលបិតក្នុងសតវត្សទី១៩ គឺអាចមានពត៌មានកាលបរិច្ឆេទ។

[៥] Phasook Indrawooth 2004:133

[៦] John N. Miksic 2003:3

[៧] httpswww.facebook.comKhmer440photostwo-seventh-century-khmer-gold-coins

[៨] Howard A. Daniel III 2012:17

[៩] Howard A. Daniel III 2012:21-30

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ការលេចឡើងនៃកាក់កម្ពុជាដែលមានរូប និងកាលបរិច្ឆេទច្បាស់លាស់នៅលើកាក់នោះ គឺឆ្នាំគ.ស១៨៤៦ ដែលគេអាចដឹងថាប្រហែលជាផលិតនៅក្រុងឧត្តុង្គ ដោយក្រុមហ៊ុនអង់គ្លេសជាមួយកម្ពុជា[១០] (រូបលេខ៦)[១១]។ ក្រៅពីនេះ កាក់ដែលមានកាលបរិច្ឆេទច្បាស់លាស់ និងមានព្រះឆ័យល័ក្ខរបស់ព្រះមហាក្សត្រផងនោះ គឺកាក់ក្នុងរជ្ជកាលព្រះបាទនរោត្តម ដែលផលិតក្នុងឆ្នាំគ.ស១៨៦០ (រូបលេខ៧)។[១២] ក្រោយមក បារាំងដែលបានគ្រប់គ្រងប្រទេសឥណ្ឌូចិន (កម្ពុជា វៀតណាម និងឡាវ) បានផលិតកាក់មួយប្រភេទដើម្បីប្រើប្រាស់ជារួមក្នុងប្រទេសទាំង៣នេះ ដែលយើងឃើញមានវត្តមានពីឆ្នាំគ.ស១៨៩៦ ដល់គ.ស១៩២១ (តែអវត្តមានឆ្នាំ១៩០៤ ១៩០៥ និង១៩១៥) (រូបលេខ៨)។[១៣] ការផលិត និងប្រើប្រាស់កាក់នៅកម្ពុជាបានបន្តរហូតដល់សម័យសង្គមរាស្ត្រនិយម សម័យលន់ នល់ និងចុងក្រោយគឺសម័យរដ្ឋកម្ពុជា។ ក្រោយឆ្នាំ១៩៩៤ កាក់មិនត្រូវបានផលិត និងឈប់ប្រើប្រាស់ជាផ្លូវការក្នុងប្រទេសកម្ពុជា រហូតមកដល់សព្វថ្ងៃ។

ចំនុចទាំងនេះ គ្រាន់តែជាការលើកឡើងត្រួសៗអំពីវត្តមានកាក់ក្នុងប្រទេសកម្ពុជាពីសម័យបុរាណមកដល់បច្ចុប្បន្នប៉ុណ្ណោះ។ ចំពោះការសិក្សាស្រាវជ្រាវលម្អិតអំពីកាក់ទាំងនោះតាមបែបបុរាណវិទ្យា មិនទាន់មាននៅឡើយទេ លើកលែងតែកាក់ដែលរកបានដោយលោក ម៉ាឡេរ៉េនៅអូរអែវ។ ដូចនេះ វាទាមទារឱ្យមានការសិក្សា និងប្រមូលទិន្នន័យបន្ថែមពីកំណាយបុរាណវិទ្យា ដើម្បីកំណត់ឱ្យបានច្បាស់លាស់លើកាក់ដែលមានវត្តមានក្នុងទឹកដីកម្ពុជាបុរាណ។

[១០] Groslier, George, 1921:32-33

[១១] https://www.coinshome.net/en/coin_definition-1_Tical-Silver-Cambodia

[១២] https://www.coinshome.net/en/coin_definition-10_Centime-Bronze_Silver-Cambodia

[១៣] Hiroshi Sugiyama and al 2016:14

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

## ឯកសារពិគ្រោះ


ជួន ណាត.

១៩៦៧. *វចនានុក្រមខ្មែរ*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

Bérénice Bellina and Ian Glover.

2004. *The Archaeology of Early Contact with India and the Mediterranean World, from the Fourth Century BC to The Fourth Century AD*, in Southeast Asia from Prehistory to History, Routledge Curzon, New York, pp.68-88.

**Charles Higham.**

2002. Early Culture of Mainland Southeast Asia, River Book, Thailand, p.236.

Groslier George.

1921. *Researches Sur les Cambodgiens*, Augustin Challamel, Paris.

Hiroshi Sugiyama and al,.

2016. *Survey of Post-Angkor Site II:Report on the Examination of Artifacts Unearthed from Wat Beng Khnar*, Nara Institute and MINCF, Japan.

Howard A. Daniel III.

2012. *Cambodian Coins and Currency*, Vietnam.

https://www.coinshome.net/en/coin_definition-1_Tical-Silver-Cambodia
httpswww.facebook.comKhmer440photostwo-seventh-century-khmer-gold-coins
https://www.coinshome.net/en/coin_definition-10_Centime-Bronze_Silver-Cambodia

John N. Miksic.

2003. *The Beginning of Trades in Ancient Southeast Asia: The Rule of OC EO and the Lower Mekong River*, in Art and Archaeology of Funan:Pre-Khmer Kingdom of the Lower Mekong Valley, Bangkok, pp1-34.

Malleret L.,

1959b. *L'Achéologie du delta de Mékong: L'Exploration archéologie et les fouille d' Oc-éo*, Paris:PEFEO, XLIII-1.

Phasook Indrawooth.

2004. *The Archaedology of the Early Buddhist Kingdoms of Thailand*, in Southeast Asia from Prehistory to History, Routledge Curzon, New York, pp120-148.

Hiroshi Sugiyama and al,.

2016. *Survey of Post-Angkor Site II:Report on the Examination of Artifacts Unearthed from Wat Beng Khnar*, Nara Institute and MINCF, Japan.



រូបលេខ១៖ កាក់មកពីប្រទេសរ៉ូមាំង

(ប្រភព៖ Charles Higham 2002:236)



រូបលេខ២៖ កាក់រកឃើញនៅឥណ្ឌា និងរ៉ូមាំង

(ប្រភព៖ Malleret Louis: 1959b)



រូបលេខ៣៖ រកឃើញនៅបាថេ (វៀតណាម)

(ប្រភព៖ John N. Miksic 2003:3)



រូបលេខ៤៖ កាក់២មានសណ្ឋានជាសន្ទឹកមាស ដោយមានព្រះនាមស្តេច ឈ្មោះស្រីសានវ្ម៌

(ប្រភព៖ httpswww.facebook.comKhmer440photostwo-seventh-century-khmer-gold-coins )



រូបលេខ២៥៖ កាក់ធ្វើពីសំរឹទ្ធនាសម័យអាណាចក្រអង្គរ

(ប្រភព៖ Howard A. Daniel III 2012:17)



រូបលេខ២៦៖ កាក់ផលិតនៅក្រុងឧត្តុង្គ

(ប្រភព៖ Groslier, George, 1921:32-33)

បារាំងដែលបានគ្រប់គ្រងប្រទេសឥណ្ឌូចិន (កម្ពុជា វៀតណាម និងឡាវ)




រូបលេខ៧៖ កាក់ក្នុងរជ្ជកាលព្រះបាទនរោត្តម

(ប្រភព៖ https://www.coinshome.net/en/coin_definition-10_Centime-Bronze_Silver-Cambodia)




រូបលេខ៨៖ កាក់បារាំងប្រើប្រាស់ពេលគ្រប់គ្រងប្រទេសឥណ្ឌូចិន (កម្ពុជា វៀតណាម និងឡាវ)

(ប្រភព៖ Hiroshi Sugiyama and al 2016:14)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា